លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ

ការបណ្តុះបណ្តាលផ្នែកបរិស្ថាន (ETP)

# មេរៀនៈ H

## យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA )

## Strategic Environment Assessment

ឯកសារសំរាប់សិក្ខាកាម

# មាតិកា

~~~~

យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ........................................................................ មេរៀនទី ១

វិធីសាស្ត្រ និងបច្ចេកទេសនៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ................................ មេរៀនទី ២

អក្សរកាត់

សន្ទានុក្រម

ឯកសារយោង
~~~~

# សញ្ញាណទូទៅនៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន

ដំណើរការនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA) ត្រូវបានគេអនុវត្តន៏ជាដំបូង ទៅលើគំរោងអភិវឌ្ឍន៍ដែលបានស្នើសុំសំរាប់ទីតាំងមួយជាកំណត់ ចាប់តាំងពីពេលដែលយល់ច្បាប់អំពីសញ្ញាណទូទៅរបស់វាក្នុងសហរដ្ឋអាមេរិចនាដើមទស្សវត្សន៏ឆ្នាំ១៩៧០ ។ ទោះជាយ៉ាងនេះក្តី យើងបានឃើញរួចមកហើយតាមរយៈការប្រមើលមើលរបស់យើងទៅលើការវាយតំលៃបរិស្ថានដែលប្រមូលផ្តុំគ្នាក្នុងរយៈពេលមួយ(CEA) ដែលក្នុងនោះការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA)នៅកំរិតគំរោងជារឿយៗគឺមិនមានលក្ខណៈសមស្របសំរាប់ការធ្វើសេចក្តីសំរេចចិត្ត ក្នុងកំរិតទ្រង់ទ្រាយធំ ។ ម្យ៉ាងវិញទៀត ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA) និងការវាយតំលៃបរិស្ថានដែលប្រមូលផ្តុំគ្នាក្នុងរយៈពេលមួយ (CEA) មិនអាចផ្តល់ពតិមានគ្រប់គ្រាន់សំរាប់ការធ្វើសេចក្តីសំរេចចិត្ត ទាក់ទងទៅនឹងបញ្ហាបរិស្ថាននៅកំរិតតំបន់ កំរិតជាតិ រឺ កំរិតទ្រង់ទ្រាយធំបានឡើយ ។ តាមរបៀបមួយដូចគ្នា នៅពេលដែលការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA)នៅថ្នាក់នៅកំរិតគំរោងត្រូវបានពង្រីងទៅជាការវាយតំលៃបរិស្ថានដែលប្រមូលផ្តុំគ្នាក្នុងរយៈពេលមួយ (CEA) នោះ យុទ្ធសាស្ត្រនៃការវាយតំលៃបរិស្ថាន (SEA) អាចត្រូវបានគេចាត់ទុកថា គឺជាការពង្រីកបន្តចេញពីការវាយតំលៃបរិស្ថានដែលប្រមូលផ្តុំគ្នាក្នុងរយៈពេលមួយ (CEA) ។ បញ្ហាដែលលេចឡើងមួយក្នុងទស្សវត្តន៏ឆ្នាំ១៩៩០ គឺជាការពាក់ពន្ធ នៃតំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA) ទៅនឹងគោលនយោបាយអភិវឌ្ឍន៍ផែនការនិងកម្មវិធីបរិស្ថាន (PPPs) ។

យុទ្ធសាស្ត្រនៃការវាយតំលៃបរិស្ថាន (SEA) គឺជាតំណើរការជាលក្ខណៈប្រពន្ធ័មួយសំរាប់ធ្វើការវាយតំលៃវិបាកទាំងឡាយនៃគោលនយោបាយអភិវឌ្ឍន៏ផែនការ និងកម្មវិធីផ្សេងៗដែលទាក់ទិនទៅនឹងបញ្ហាបរិស្ថាន ។ ការវាយតំលៃនេះគឺមានបំណងដើម្បីធានាអោយបានថា ការព្រួយបារម្ភណ៏ទាក់ទិនទៅនឹងបញ្ហាបរិស្ថាន ត្រូវបានគេយកចិត្តទុកដាក់យ៉ាងពេញលេញ និងធ្វើការដោះស្រាយយ៉ាងសមស្របនៅតំណាក់ការតំបូងបង្អស់នៃការរៀបចំផែនការ ។ នៅក្នុងស្ថានភាពបែបនេះគោលនយោបាយមាននៃថាជាហេតុផលទូទៅនៃសកម្មភាព (General course of action) រឺទិសដោយរួម ដែលបានស្នើឡើង ដែលរដ្ឋាភិបាលត្រូវធ្វើការតាមដាន រឺអនុវត្តន៏ ហើយដែលអាចណែនាំ ដល់ការធ្វើសេចក្តីសំរេចចិត្តដែលកំពុងដំណើការ ។ ផែនការមួយត្រូវបានគេកំណត់ថាជាគោលបំណងមួយ ដែលជារឿយៗធ្វើឡើងដោយមានការសំរបសំរួលនូវ អត្ថភាពគោលដៅជ្រើសរើស និងវិធានការផ្សេងៗដែលបកស្រាយ និងប្រតិបត្តិគោលនយោបាយ ។ ជាចុងក្រោយ កម្មវិធីមួយជាសញ្ញានៃការទាក់ទងគ្នាជារនឹកហូរហែរមួយ ជារបៀបវីរៈប្រកបដោយការគ្រប់គ្រងល្អ រឺជាកម្មវិធីនៃការប្តេជ្ញចិត្តក្នុងការអនុវត្តន៏អ្វីមួយ នៃការស្នើសុំនៃឧបករណ៏ផ្សេងៗ និង/រឺ សកម្មភាពដែលបកស្រាយ និងប្រតិបត្តិគោលនយោបាយ ។

សារៈសំខាន់នៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន (SEA) គឺដើម្បីធ្វើការវាយតំលៃគោលនយោបាយអភិវឌ្ឍន៍ផែនការ និងកម្មវិធីទាំងឡាយណាដែលទាក់ទិនទៅនឹងបញ្ហាបរិស្ថាន ( PPPs ) ដើម្បីធ្វើការកំណត់ប្រសិទ្ធភាពរបស់វា ។ គោលនយោបាយបរិស្ថាន ដែលបានសរសេឡើងដ៏ល្អបំផុត រឺកម្មវិធីបរិស្ថានដែលល្អបំផុត គឺគ្មានតំលៃទាល់តែសោះ

ប្រសិនបើវាមិនបានជួយសំរួលដល់ការសំរេចបាននូវលទ្ធផលជាបន្តបន្ទាប់ នូវគោលដៅនៃការអភិរក្ស រឺការគ្រប់គ្រងធនធាននៃប្រទេសមួយ ។ គោលនយោបាយ និងកម្មវិធីបរិស្ថានត្រូវតែធ្វើការវាយតំលៃជាប្រចាំចំពោះប្រសិទ្ធិភាពរបស់វាហើយតាមរយៈការដាក់បំរាមជាដំបូង គឺអាចជួយបំពេញបន្ថែមនូវក្នុងដំណើរការនៃយុទ្ធសាស្រ្តបរិស្ថាន នោះវាអាចត្រូវបានគេប្រើប្រាស់យ៉ាងប្រសើរដើម្បីប្រសិទ្ធិភាពបរិស្ថាន ។

យុទ្ធសាស្រ្តវាយតំលៃបរិស្ថាន (SEA) ជាតំណាងអោយ កាឡានុវត្តន៏ភាពពិសេសមួយសំរាប់ប្រជាជាតិនៅតាមដងទន្លេ នៃអាងទន្លេមេគង្គ ( MRB ) ដើម្បីធ្វើការត្រួតពិនិត្យបន្តទៀតនូវការប្រើប្រាស់ និងកិច្ចអភិវឌ្ឍន៏ធនធានធម្មជាតិរបស់ខ្លួន ។ ជាមួយនឹងស្ថានភាពដែលគោលនយោបាយ និងកម្មវិធីបរិស្ថានជាច្រើនបាន និងកំពុងបង្កើនឡើង (តារាង ១) នៅក្នុងអាងទន្លេមេគង្គ ( MRB ) បណ្តាអ្នកគ្រប់គ្រងបរិស្ថានអាចធ្វើការវាយតំលៃសក្តានុពលនៃប្រសិទ្ធិភាពនៃកម្មវិធីការពារបរិស្ថានថ្មីៗ មុនពេលដែលកម្មវិធីទាំងនេះត្រូវបានគេប្រតិបត្តិ ។ ហេតុនេះចំណុចខ្សោយទាំងឡាយអាចត្រូវបានគេកំណត់ និងដោះស្រាយមុនពេលការធ្វើសេចក្តីសំរេចចិត្តលើការគ្រប់គ្រងធនធាន ដែលមានសភាពធ្ងន់ធ្ងរ រឺមិនអាចជួសជុលបានត្រូវបានធ្វើឡើង ។

ផែនការបរិស្ថានដែលមានប្រសិទ្ធិភាពអាចអោយគេដឹងបានតាមរយៈការធ្វើផែនការ និងការអនុវត្តន៏យុទ្ធសាស្រ្តវាយតំលៃបរិស្ថាន ( SEAs )។ ឧទាហរណ៏យុទ្ធសាស្រ្តវាយតំលៃបរិស្ថាន អាចជួយផ្តល់នូវការព្រួយបារម្ភរណ៏ ទាក់ទិនទៅនឹងបញ្ហាបរិស្ថានផ្សេងៗដែលមានសារៈសំខាន់ស្រដៀងគ្នា ទៅនឹងសារៈសំខាន់នៃទស្សនៈទាននៃការអភិវឌ្ឍន៏ (ឧទាហរណ៏ : សេដ្ឋកិច្ចតំរូវការទីផ្សារ ហិរញ្ញវត្ថុ និងបច្ចេវិជ្ជា) ក្នុងការធ្វើសេចក្តីសំរេចចិត្ត ។ វាក៏អាចជួយលើកទឹកចិត្តដល់ការកំណត់គោលដៅបរិស្ថានដែលស្របគ្នា ទៅនឹងគោលដៅខាងផ្នែកសង្គម និងសេដ្ឋកិច្ច ។

**តារាង ១: ឧទាហរណ៍: នៃសក្ដានុពលភាព នៃការពាក់ពាន្ធ័របស់យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) ក្នុងអាងទន្លេមេគង្គ ( MRB )**

| | គោលនយោបាយ | ផែនការ | កម្មវិធី |
|---|---|---|---|
| កម្ពុជា | ផែនការសកម្មបរិស្ថានជាតិសំរាប់ព្រះរាជាណាចក្រម្ពុជា | ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជា | |
| ឡាវ | ផែនការសកម្មភាពបរិស្ថានជាតិ | ក្រឹត្យលេខ ១១៨ ស្ដីពីការគ្រប់គ្រង និងការការពារសត្វព្រៃជលផល និងស្ដីអំពីការបបាញ់ និងការនេសាទ | គោការណ៏ណែរនាំសំរាប់ការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន នៃគំរោងសាងស់ងផ្លូវថ្នល់ ក្នុងសាធារណៈរដ្ឋ-ប្រជាមានិតុ ប្រជាធិបតេយ្យឡាវ |
| ថៃ | សេចក្ដីសំរេចស្ដីពីការជំរុញ និងការអភិរក្សគុណភាពបរិស្ថានជាតិ | សេចក្ដីសំរេចស្ដីពីការអភិរក្ស និងការការពារសត្វព្រៃ | បទដ្ឋានគុភាពទឹកលើដី |
| វៀតណាម | ផែនការសកម្មភាពជីវៈចំរុះវៀតណាម | ច្បាប់ស្ដីពីកិ ច្ចការពារបរិស្ថាន | បទដ្ឋានគុណភាពទឹកលើដី |

យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ត្រូវតែត្រូវបានពិនិត្យឡើងវិញនូវក្នុងស្ថានភាពរួមនៃការសិក្សា អំពីហេតុប៉ះពាល់ដែលពាក់ពន្ធ័ទៅនឹងការបង្កើតគោលនយោបាយផែនការនឹងកម្មវិធីបរិស្ថាន ហើយនិងការវាយតំលៃហេតុប៉ះពាល់បរស្ថានក៏រិតគំរោង ។ នៅក្នុង ស្ថានភាពជាច្រើនយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ត្រូវបានបង្កើនប្រសិទ្ធិភាព ខាងផ្នែករដ្ឋបាលតាមរយៈការរៀបចំជាលំដាប់ជាន់ថ្នាក់ (Tiering) ដែលជាដំណើរការមួយ ដែលការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIAs) ត្រូវបានគេអនុវត្តជាដំបូងនូវក៏រិតគោលនយោបាយ រឺកម្មវិធី ហើយបន្ទាប់មកការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIAs) ជំហ៊ានបន្ទាប់ទៀតត្រូវបានគេអនុវត្តនូវក៏រិតជាន់ក្រោមៗទៀត ពោលគឺក៏រិតគំរោង ។ ការរៀបចំជាក៏រិតជាន់ថ្នាក់ ( Tiering ) គឺជួយជំរុញនូវប្រសិទ្ធិភាពកាលណាគំរោងស្នើសុំមានសង្គតភាពជាមួយបណ្ដាគំរោង ដែលត្រូវបានគេគិតគួររួចរាល់នៅក៏រិតជាន់ថ្នាក់មួយខ្ពស់ជាងនេះ ។ ( ពោលគឺក៏រិតយុទ្ធសាស្ត្រវាតំលៃបរិស្ថាន " SEA " ) ។ ក្នុងករណីនេះការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA) ក៏រិតគំរោងអាចបានដល់អ្វីដែលថាប្រសើជាង " Redo " …??? ដែលការវិភាគផ្សេងៗត្រូវបានអនុវត្តរួចជាស្រេចនៅក្នុងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA) ។ ទោះជាយ៉ាងនេះក្ដីការរៀបចំជាជាន់ថ្នាក់អាចត្រូវបានគេប្រើប្រាស់ដោយខុសរបៀប រឺភាន់ច្រឡំ ប្រសិនបើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA) នៅក៏រិតគំរោងមិនត្រូវបានគេអនុវត្តដោយហ្មត់ចត់ព្រះថាវាត្រូវបានគេសន្មត់ថា ហេតុប៉ះពាល់បរិស្ថានថ្នាក់គំរោងត្រូវបានគេធ្វើការវាយតំលៃយ៉ាងសមស្របរួចហើយនៅក្នុងយុទ្ធសាស្ត្រ វាយតំលៃបរិស្ថាន ( SEA) ។ ការ

ប្រើប្រាស់ខុសរបៀប រឺដោយភាន់ច្រឡំនេះ អាចកើតមានឡើងព្រោះថា គំរោងដែលត្រូវបានបញ្ចូលនៅក្នុងយុទ្ធសាស្ត្រវាយតំលៃបរិស្ថានជាទូទៅត្រូវបានគេកំណត់លក្ខណៈនៅក្នុងលក្ខ័ខណ្ឌ័ដ៏ទូទៅមួយ ។

ជារឿយៗ គំរោងទ្បាំងឡាយ ត្រូវបានគេបញ្ចូលយ៉ាងសមស្របនៅក្នុងយុទ្ធសាស្ត្រវាយតំលៃបរិស្ថានមួយមុនពេលប៉ារ៉ាម៉ែត្រសំខាន់ៗត្រូវបានគេកំណត់ ។ នៅក្នុងសមត្ថកិច្ចមួយចំនួន(ឧទាហរណ៍ ក្នុងចក្រភពអង់គ្លេស) យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន និងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន នៅកំរិតគំរោង ត្រូវបានគេញែកដាច់ពីគ្នាដោយចេតនាដើម្បីធានាអោយបានថាការវិភាគដ៏ពិស្តារដែលត្រូវការនៅក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIAs) កំរិតគំរោងគឺមិនចាំបាច់ត្រូវបង់ខាតដោយការបង្កើតឯកសារយោងដែលមានលក្ខណៈដ៏ទូទៅដែលការវិភាគគុណភាពត្រូវបានគេបញ្ចូលជាពិសេស ទៅក្នុងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEAs) ។ ដើម្បីបង្ហាញអំពីទំនាក់ទំនងនេះ រូបទី ១ គឺពណ៌នាអំពីប្រពន្ធ័កំរិតជាន់ថ្នាក់នៃការធ្វើផែនការ និងការសិក្សាហេតុប៉ះពាល់បរិស្ថាន ។ ប្រពន្ធ័នេះមាន លក្ខណៈអាចអោយអនុវត្តន៏ជាទូទៅបានគ្រប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៏ និងជឿនលឿនទាំងអស់ ។ ទោះជាយ៉ាងនេះក៏ដោយគេត្រូវទទួលស្គាល់ថា វាត្រូវបានគេបង្កើតឡើងដោយយោងទៅលើការប្រើប្រាស់ដី និងការអនុវត្តន៏ជាក់ស្តែងនៃការធ្វើផែនការបរិស្ថាននៅចក្រភពអង់គ្លេស ហើយចាំបាច់ត្រូវតែធ្វើការបន្សាំទៅនឹងស្ថានភាពជាក់ស្តែង ដើម្បីអោយស៊ីគ្នាទៅនឹងការអនុវត្តន៏ជាក់ស្តែងក្នុងប្រទេសណាមួយ ។

## រូបទី ១ : ឧទាហរណ៍ នៃកំរិតប្រព័ន្ធជាន់ថ្នាក់សំរាប់ការសិក្សាហេតុប៉ះពាល់បរិស្ថាន

| | | សកម្មភាពតាមវិធី និងពហុវិស័យ<br>ការវាយតំលៃចំណាត់ថ្នាក់ និងប្រភេទនៃសកម្មភាព (ក្នុងវង់ក្រចក ) | | | |
|---|---|---|---|---|---|
| កំរិតរដ្ឋាភិបាល | ផែនការប្រើប្រាស់ដី ( SEA ) | គោលនយោបាយ ( SEA ) | ផែនការ ( SEA ) | កម្មវិធី ( SEA ) | គំរោង ( SEA ) |
| ថ្នាក់ជាតិ/ថ្នាក់ប្រទេស | ផែនការប្រើប្រាស់ថ្នាក់ជាតិ | គោលនយោបាយដឹកជញ្ជូនថ្នាក់ជាតិ<br>គោលនយោបាយសេដ្ឋកិច្ចជាតិ | ផែនការរៀបចំផ្លូវរយៈពេលវែងថ្នាក់ជាតិ | កម្មវិធី ៥ ឆ្នាំនៃការស្ទង់សង់ផ្លូវ | ផ្នែកសាងសង់ផ្លូវ ( Motoway ) |
| ថ្នាក់តំបន់/រដ្ឋ | ផែនការប្រើប្រាស់ដីថ្នាក់តំបន់ | | ផែនការយុទ្ធសាស្ត្រថ្នាក់តំបន់ | កម្មវិធីវិនិយោគថ្នាក់អនុតំបន់ | |
| ថ្នាក់អនុតំបន់ | ផែនការប្រើប្រាស់ថ្នាក់អនុតំបន់ | | | | |
| ថ្នាក់មូលដ្ឋាន | ផែនការប្រើប្រាស់ដីថ្នាក់មូលដ្ឋាន | | | | គំរោងហេដ្ឋារចនាសម្ព័ន្ធថ្នាក់មូលដ្ឋាន |

នេះគឺការសង្កេតអោយងាយយល់នៃអ្វីដែលជាការពិតជាក់ស្តែង ហើយដែលអាចមានទំនាក់ទំនងដ៏ស្មុគ្រស្មាញជាងនេះ ។ ជាទូទៅ សកម្មភាពទាំងនេះនៅកំរិតជាន់ថ្នាក់ខ្ពស់បំផុត( ឧទាហរណ៏ គោលនយោបាយថ្នាក់ជាតិ) ជាទូទៅគឺត្រូវការចាំបាច់នូវទ្រង់ទ្រាយដ៏ទូលំទូលាយ និងមានលក្ខណៈងាយនៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ។

**ការប្រៀបធៀបយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) និងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) កំរិតគំរោង:**

ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIAs ) កំរិតគំរោងគឺបានទទួលនូវការរិះគន់យ៉ាងខ្លាំង ។ គុណវិបត្តិជាទូទៅមួយគឺមានដូចតទៅ :

- ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) ត្រូវបានគេអនុវត្តយ៉ាងយឺតយ៉ាវ នៅក្នុងវដ្តនៃគំរោងដែលបញ្ហានេះជះឥទ្ធិពលទៅដល់កត្តាសំរេចចិត្តផ្សេងៗ ។
- វិធានការកែលំអរដែលបានស្នើឡើងជារឿយៗ មិនត្រូវបានគេអនុវត្ត
- ការត្រួតពិនិត្យហេតុប៉ះពាល់បរិស្ថាន រឺវិធានការកែលំអរនៅក្រោយពេលបញ្ចប់គំរោងមានតិចតួចបំផុត ។
- ហេតុប៉ះពាល់បរិស្ថានដែលប្រមូលផ្តុំគ្នា ( Cumulative impacts ) មិនត្រូវបានគេវិភាគ អោយបានសមស្រប ។
- ពុំមានការយកចិត្តទុកដាក់ រឺចាប់អារម្មអោយបានគ្រប់គ្រាន់ ទៅលើការវាយតំលៃភាពដែលអាចមានគ្រោះថ្នាក់ រឺការខ្វះខាតហេតុប៉ះពាល់សង្គម និងភាពមានគ្រោះថ្នាក់ រឺខ្វះខាតចំពោះសុខភាព ។
- ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) ត្រូវបានគេអនុវត្តជាតំបូងសំរាប់គំរោង ប៉ុន្តែជាទូទៅគឺមិនត្រូវបានអនុវត្តសំរាប់កម្មវិធី រឺគោលនយោបាយដែលពាក់ពន្ធ័ ។

ភាពដ៏មានកំរិតទាំងនេះ ពិសេស គឺបញ្ហាពាក់ពន្ធ័ទៅនឹងការយឺតយ៉ាវ ការកំណត់ពេលវេលានៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) នៅក្នុងវដ្តនៃគំរោង និងការខ្វះខាតការយកចិត្តទុកដាក់ នៅក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃគំរោងចំពោះហេតុប៉ះពាល់ដែលប្រមូលផ្តុំគ្នាអាចអោយគេសំរេចជោគជយ័ទៅបានតាមរយៈការអនុវត្តន៏យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEAs ) ។ ប្រហែលជាទ្រង់ទ្រាយដ៏ទូទៅបំផុតនៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) គឺជាការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃផែនការប្រើប្រាស់ដីនៅកំរិតជាន់ថ្នាក់ទីប្រជុំជន និងតំបន់ ។

យុទ្ធសាស្ត្រវាយតំលៃបរិស្ថានអាចដោះស្រាយភាពមានកំរិត រឺដែនកំណត់នៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) កំរិតគំរោងតាមរយៈ ៖-

- ការបង្កើនកាលានុវត្តិន៏ភាព ដើម្បីជះឥទ្ធិពលទៅលើគំរោង
- ការគិតគួរ ពិចារណាអំពីជំ រើសដ៏ទូលំទូលាយ
- បង្កើនគុណភាពនៃការវិភាគហេតុប៉ះពាល់បរិស្ថានដែលប្រមូលផ្តុំគ្នា
- ការបង្កើនប្រសិទ្ធិភាពតាមរយៈការរៀបចំជាកំ រិតជាន់ថ្នាក់ ( Tiering )

ដោយសារយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) កើតឡើងមុនការធ្វើសេចក្តីសំរេចចិត្តនៅកំរិតគំរោងនោះ យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEAs ) អាចចាត់ទុកជាសកម្មភាពដែលជាជំរើសមួយលំដាប់ ដែលអាចមានលក្ខណៈពេញលេញហើយវាអាចបង្កើនគុណភាពនូវរបៀបដែលកត្តាបរិស្ថានផ្សេងៗ ត្រូវបានគេបញ្ចូល ទៅក្នុងការធ្វើសេចក្តីសំរេចចិត្តនៅថ្នាក់គំរោង ។ លើសពីនេះទៀតដោយសារតែទ្រង់ទ្រាយភូមិសាស្ត្រ ជារឿយៗ វាមានទំហំធំទូលាយ

នោះយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) ផ្តល់នូវអាចជាឧបករណ៏មួយសំរាប់ត្រួតពិនិត្យ ឥទ្ធិពលជះដែលប្រមូលផ្តុំគ្នា ទាំងឡាយរបស់គំរោងពាក់ពន្ធ័ ។

មានមធ្យោបាយជាច្រើនដែលតាមរយ:នោះ យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEAs ) ក៏រឹតគំរោង អាចត្រូវបាន គេធ្វើការប្រៀបធៀប ។ ទន្ទឹមនឹងមានលក្ខណៈច្រដៀងគ្នាជាច្រើនប៉ុន្តែវាក៏មានភាពខុសគ្នាមួយចំនួនដែរ ។ ភាពខុសគ្នាចំបង១មួយចំនួន រួមមាន ៖-

- ទំហំនៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA) : ចំពោះសកម្មភាព និងសកម្មភាពដែលពាក់ពន្ធ័ លំដាប់នៃ ជំរើសដែលត្រូវបានគេពិចារណាតំបន់ផ្ទៃភូមិសាស្ត្រនៃការសិក្សា និងលំដាប់នៃហេតុប៉ះពាល់ ដែលពាក់ពន្ធ័ មានទំនោរដូចជាធំជាងបើប្រៀបធៀបទៅ នឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) ។
- ចន្លោះពេលរវាងការអនុវត្តន៏យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) និងប្រតិបត្តិការណ៏នៃសកម្មភាពមួយ ចំនួនជាកំណត់ ជាទូទៅ គឺមានរយៈពេលវែងជាងបើប្រៀបធៀបទៅនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) ។
- ការពាក់ពន្ធ័ទៅនឹងបច្ចេកទេស ហើយនឹងលក្ខណៈបច្ចេកទេសរបស់យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) គឺមានលក្ខណៈ រឺពិស្តារតិចជាងបើប្រៀបធៀបទៅ នឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) ។
- ភាពមិនប្រាកដនៃការព្យាករណ៏ផលប៉ះពាល់ គឺមានទំហំធំជាងចំពោះយុទ្ធសាស្ត្រ វាយតំលៃបរិស្ថាន ( SEA) បើប្រៀបធៀបទៅ នឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) ។

## **គុណសម្បត្តិ (ការប្រើប្រាស់) នៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន** (SEA)

គុណសម្បត្តិសំខាន់បីនៃយុទ្ធ សាស្ត្រវាយតំលៃបរិស្ថាន ( SEA ) គឺ៖-

១- ជាមធ្យោបាយមួយក្នុងការពង្រឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) ក៏រឹតគំរោង

២- ដើម្បីដោះស្រាយឥទ្ធិពលជះដែលប្រមូលផ្តុំគ្នា និងដែលមានទ្រង់ទ្រាយធំ

៣- ដើម្បីបញ្ចូលការគិតគូរពិចារណអំពី និរន្តភាព រឺចីរភាពទៅក្នុងការធ្វើសេចក្តីសំរេចចិត្ត ។

លើសពីនេះទៀតយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) ជួយសំរួលដល់ការគិតគូរពិចារណា អំពីវិធីសាស្ត្រ ដែលជាជំរើសហេតុប៉ះពាល់ថ្នាក់តំបន់ រឺថ្នាក់ពិភពលោក និងហេតុប៉ះពាល់ក្រៅគំរោងដែលអាច បណ្តាលមកពីការ ធ្វើសេចក្តីសំរេចចិត្តនៅក្នុងការងារគ្រប់គ្រងផ្សេង១ ។ ប្រភេទនៃផលប៉ះពាល់ទាំងនេះ អាចត្រូវបានគេវាយតំលៃ ប្រកបដោយលក្ខណៈល្អប្រសើជាដំបូងគឺនៅលំដាប់នៃការបង្កើតគោលនយោបាយ ផែនការ និងកម្មវិធីបរិស្ថាន ដែល ប្រសើជាងនៅលំដាប់គំរោង ។

អត្ថប្រយោជន៏ខ្លះទៀតនៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) រួមមាន ៖-

- លើកទឹកចិត្តដល់ការគិតគូរពិចារណាអំពីគោលបំណងទាក់ទិនទៅ នឹងបរិស្ថាននៅក្នុងកំឡុងពេលធ្វើ សកម្មភាពបង្កើតគោលនយោបាយផែនការ និងកម្មវិធីបរិស្ថាន ( PPPs ) ។

- ជួយសំរួលដល់ការពិគ្រោះយោបល់ រវាងស្ថាប័នរដ្ឋាភិបាល និងជំរុញការចូលរួមពីសាធារណៈ នៅក្នុងការវាយតំលៃទស្សន ទានបរិស្ថាននៃការបង្កើតគោលនយោបាយផែនការ និងកម្មវិធីបរិស្ថាន ។
- អាចផ្តល់នូវភាពសាមញ្ញខ្លះៗការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) ក៏រិតគំរោង ប្រសិនបើហេតុប៉ះពាល់ត្រូវបានគេវាយតំលៃរួចហើយនៅក្នុងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) ។
- អនុញ្ញាតអោយបង្កើតបមាណើ វីបទដ្ឋាន វីវិធានការកែលំអរសំរាប់គំរោងក្រោយៗទៀត ។
- លើកទឹកចិត្តដល់ការគិតគូរពិចារណាអំពីជំរើសផ្សេងៗដែលជារឿយៗត្រូវបានគេទាត់ចោល វីមិនបានមើលឃើញនៅក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) គំរោង ។
- អាចជួយដល់ការកំណត់ទីតាំងសមស្រប សំរាប់គំរោងបន្តបន្ទាប់ទៀត ។
- លើកទឹកចិត្ត និងជួយសំរួលដល់ការគិតគូរពិចារណាអំពីឥទ្ធិពលជៈដែលចេះតែកើនឡើង ។
- អនុញ្ញាតអោយធ្វើការគិតគូរពិចារណាប្រកបដោយប្រសិទ្ធិភាពអំពីឥទ្ធិពលជៈ និងសកម្មភាពបន្ទាប់បន្សំ ។
- ជួយសំរួលដល់ការគិតគូរពិចារណា អំពីហេតុប៉ះពាល់ដែលមានលំដាប់ជាន់ថ្នាក់ច្រើន និងមានរយៈពេលយូរ ។
- អនុញ្ញាតអោយធ្វើការវិភាគ អំពីរហេតុប៉ះពាល់នៃគោលនយោបាយដែលមិនបានប្រតិបត្តិឆ្លងកាត់គំរោង ។

## ការលំបាក (ឧបសគ្គ) ដែលពាក់ពន្ធ័នៅនឹងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន (SEA)

ទន្ទឹមនឹងវត្តមាននៃអត្ថប្រយោជន៍ដ៏ច្រើន ចេញពីការធ្វើផែនការ និងការអនុវត្តន៏យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន (SEAs) គេក៏បានឃើញ វីជួបប្រទះនូវការលំបាក និងក៏រិតកំណត់ វីភាពមានក៏រិតមួយចំនួននូវក្នុងការអនុវត្តន៏បញ្ហានេះដែរ ។ ជាវិបាក គឺទន្ទឹមនឹងសក្តានុពលភាពនៃគុណសម្បត្តិរបស់យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEAs ) ត្រូវបានគេពិភាក្សាអស់រយៈពេលជាងមួយទស្សវត្តន៏នៅក្នុងឯកសារការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) ការប្រើប្រាស់យុទ្ធសាស្ត្រវាយតំលៃបរិស្ថាននៅតែត្រូវបានគេអនុវត្តនៅក៏រិតជាន់ថ្នាក់ ថ្នាក់ក្រោម ។ មូលហេតុខ្លះដែលបណ្តាប្រទេសជាច្រើនមិនព្រមអនុវត្តន៏ វីគិតគូរពិចារណាដោយសេចក្តីសាទរ អំពីយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEAs ) គឺៈ-

- ភាពខ្វះខាតសុឆន្ទៈខាងផ្នែកនយោបាយ និងភាពប្តេជ្ញចិត្តចំពោះការអនុវត្តន៏យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន
- ការខ្វះខាតបទពិសោធន៏ និងគោលការណ៏ណែនាំ
- ការខ្វះខាតការសំរបសំរួលក្នុងចំពោះ បណ្តាក្រសួង និងស្ថាប័នរដ្ឋាភិបាល
- ភាពមិនប្រាកដ និងភាពដ៏ទូទៅនៅក្នុងការកំណត់និយមនយ័ នៃការបង្កើតគោលនយោបាយផែនការ និងកម្មវិធីបរិស្ថាន ( PPPs )
- សេចក្តីត្រូវការលើការចំណាយ និងពេលវេលា

ឧបសគ្គ ដ៏សំខាន់មួយដែលត្រូវបានគេកំណត់ឃើញ នូវក្នុងការបង្កើតគោលនយោបាយផែនការ និងកម្មវិធីបរិស្ថាន ( PPPs ) ជារឿយៗ គឺការគ្មានភាពច្បាស់លាស់នៅក្នុងពេលវេលា នៅពេលដែលការសំរេចចិត្តត្រូវបានគេធ្វើឡើង ។ ឧបសគ្គផ្សេងទៀតគឺនៅពេលដែលការព្រួយបារម្ភអំពី បញ្ហាបរិស្ថានដ៏ទូលំលាយ ដែលជារឿយៗ ត្រូវបាគេដោះស្រាយ

នៅក្នុងសកម្មភាពធ្វើផែនការជាទូទៅសំរាប់តំបន់ភូមិសាស្ត្រ រដ្ឋ រឺប្រទេសមួយចំនួនតាមរយៈច្បាប់ស្តីពីការប្រើប្រាស់ដី និងការធ្វើផែនការប្រើប្រាស់ដី គឺមិនមែនគ្រប់ទស្សនៈទាន រឺបញ្ហាទាំងអស់ត្រូវបានគេគិតគូរពិចារណានោះទេ ។ ការខ្វះខាតសុឆន្ទៈខាងផ្នែកនយោបាយ ក៏ជាឧបសគ្គដ៏ទូទៅមួយដែរ ។ ជារឿយៗ កត្តាដែលធ្វើអោយរអែង រឺញញើត ជាចំបង ចំពោះយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) គឺបញ្ហានយោបាយ : បណ្តាស្ថាប័នរដ្ឋាភិបាលមានការស្ទាក់ស្ទើរ រឺទើសទាល់ដោយធ្វើការពន្យាពេលនៅក្នុងតួនាទីនៃការធ្វើសេចក្តីសំរេចចិត្តរបស់ខ្លួនចំពោះបណ្តាភាគីផ្សេងទៀត តាមរយៈការស្នើសុំយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEAs ) នៃសកម្មភាពរបស់ពួកគេ ។

ឧបសគ្គផ្សេងៗទៀតចំពោះការប្រើប្រាស់ដ៏ធំធេងនៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEAs ) រួមមាន ៖-

- ការខ្វះខាតចំណេះដឹង និងបពិសោធន៏ ( ឧទាហរណ៏ : ការកំណត់អោយដឹងថា តើកត្តាបរិសានណាខ្លះដែលត្រូវធ្វើការគិតគូរពិចារណាតើហេតុប៉ះពាល់បរិស្ថានអ្វីខ្លះដែលអាចកើតមានឡើង ហើយតើការបង្កើតគោលនយោបាយចំរុះយ៉ាងដូចម្តេចដែលអាចសំរេចបានជោគជយ័)
- ការលំបាកខាងផ្នែកស្ថាបន័ និងការគ្រប់គ្រងដូចដែលបានឆ្លុះបញ្ចាំងអោយឃើញ តាមរយៈសេចក្តីត្រូវការដ៏ចាំបាច់សំរាប់ការសំរបសំរួលប្រកបដោយប្រសិទ្ធិភាពនៅក្នុង និងរវាងស្ថាបន័រដ្ឋាភិបាល
- ការខ្វះខាតធនធាន ( ឧទាហរណ៏ : -ពត៌មាន -ជំនាញ -ហិរញ្ញវត្ថុ ។ល។)
- ការខ្វះខាតគោលការណ៏ណែនាំ រឺយន្តការដើម្បីធានានូវប្រតិបត្តិការណ៏ ដ៏ពេញលេញមួយ
- ការលំបាកក្នុងការបញ្ជាក់អោយបានច្បាស់លាស់នូវក្នុងការបង្កើតគោលនយោបាយ ផែនការ និងកម្មវិធីបរិស្ថានថ្មី ( PPPs ) ហើយនិងនៅក្នុងការកំណត់ថាតើយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) ត្រូវតែត្រូវបានគេអនុវត្តនៅពេលណា និងយ៉ាងដូចម្តេច
- វិធីសាស្ត្រផ្សេងៗ មិនត្រូវបានគេបង្កើតឡើងដោយសមស្រប
- ភាពមានកំរិតនៃការចូលរួល ពីសាធារណៈនៅក្នុងការធ្វើសេចក្តីសំរេចចិត្ត ។

**ឧទាហរណ៏ : នៃសេចក្តីត្រូវការ រឺភាពចាំបាច់នៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន** (SEA)

បណ្តាប្រទេស រឺខេត្តជាច្រើននៅក្នុងប្រទេសជាច្រើន មានសេចក្តីត្រូវការជាចាំបាច់ដោយផ្ទាល់ រឺដោយប្រយោលទាក់ទិនទៅនឹងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA )។ ឧទាហរណ៏ : បណ្តាខេត្ត រឺរដ្ឋមួយចំនួនរួមមាន អូស្ត្រាលីភាគខាងលិច អូស្ត្រាលីភាគខាងត្បូង និងរដ្ឋកាលីហ្វ័រញ៉ា ។ ឧទាហរណ៏ : នៃបណ្តាប្រទេស ដែលមានសេចក្តីត្រូវការនេះរួមមាន អូស្ត្រាលី ចក្រពភអង់គ្លេស កាណាដា ហូឡង់ នូវ៉ែលសេឡង់ និងសហរដ្ឋអាមេរិច ។ សេចក្តីត្រូវការនេះ អាចជាមូលដ្ឋាននៃលិខិតបទដ្ឋានច្បាប់ បទបញ្ជារដ្ឋបាល រឺគោលការណ៏ណែនាំផ្សេងៗ រឺនយោបាយនៃការធ្វើប្រតិបត្តិការណ៏ ។

នៅសហរដ្ឋអាមេរិច បទបញ្ជារបស់ក្រុមប្រឹក្សាស្តីពី គុណភាពបរិស្ថាន ( CEQ )មានចែងអំពីទស្សនៈទាន និងនិយមនយ័ផ្សេងៗពាក់ពន្ធ័ទៅនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA )។ បទបញ្ជាទាំងនេះក៏ រួមបញ្ចូលផងដែរនូវទស្សនៈទាននៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA )ហើយទោះបីជាការសង្កត់ធ្ងន់ រឺយកចិត្តទុកដាក់របស់គេ

គឺទៅលើអ្វីដែលគេហៅថា កម្មវិធីនៃរបាយការណ៍ស្តីពី ហេតុប៉ះពាល់បរិស្ថាន ( Programmatic Environmental Impact Statements - EISs - ) និងការរៀបចំជាកំរិតជាន់ថ្នាក់ ( Tiering )។ ជាគោលការណ៍គ្រឹះ កម្មវិធីនៃរបាយការណ៍ស្តីអំពីហេតុប៉ះពាល់បរិស្ថាន ( EIS ) គឺជាប្រការចាំបាច់ចំពោះសកម្មភាពសំខាន់ៗរបស់រដ្ឋាភិបាល ។ សកម្មភាពទាំងនេះអាចរាប់បញ្ចូលនូវគោលនយោបាយ ផែនការ និងកម្មវិធីបរិស្ថាន ( PPPs) ។ កម្មវិធីនៃរបាយការណ៍ស្តីពីហេតុប៉ះពាល់បរិស្ថាន ( EISs ) គឺមានការទាក់ទងទៅ នឹងរបាយការណ៍ស្តីពី ហេតុប៉ះពាល់បរិស្ថានកំរិតគំរោងតាមរយៈការរៀបចំជាកំរិតជាន់ថ្នាក់ (Tiering) ។ ស្ថាប័នរដ្ឋាភិបាលទាំងឡាយ ក្នុងសហរដ្ឋអាមេរិក ត្រូវបានលើកទឹកចិត្តអោយធ្វើការរៀបចំជាកំ រិតជាន់ថ្នាក់ នូវរបាយការណ៍ស្តីពីហេតុប៉ះពាល់បរិស្ថាន ( EISs ) របស់ខ្លួនដើម្បីលប់បំបាត់ការពិភាក្សាដដែលៗនៃបញ្ហាដូចគ្នា និងដើម្បីផ្តោតការសង្កត់ធ្ងន់ទៅលើបណ្តាបញ្ហាជាក់ស្តែងមានលក្ខណៈសមស្របសំរាប់ការធ្វើសេចក្តីសំរេចនៅកំរិតជាន់ថ្នាក់និមួយៗនៃការពិនិត្យឡើងវិញបញ្ហាបរិស្ថាន ។ ជួនកាលរបាយការណ៍ស្តីពីហេតុប៉ះពាល់បរិស្ថាន ( EIS ) ដ៏ទូលំទូលាយមួយអាចត្រូវបានគេរៀបចំដើម្បីដោះស្រាយបញ្ហាព្រួយបារម្ភអំពីបរិស្ថានជាទូទៅទាំងឡាយនៃកម្មវិធីណាមួយ រឺសេចក្តីថ្លែងការនៃគោលនយោបាយណាមួយ ។ បន្ទាប់មក សេចក្តីថ្លែងការ រឺរបាយការណ៍ ជាពិសេសណាមួយ រឺការវាយតំលៃបរិស្ថានណាមួយអាចត្រូវបានគេរៀបចំ ចំពោះសកម្មភាពមួយដែលបានរួមបញ្ចូលទៅក្នុងកម្មវិធី រឺគោលនយោបាយទាំងមូល (ឧទាហរណ៍ :សកម្មភាពនៅទីកន្លែងណាមួយជាកំណត់)។ របាយការស្តីពី ហេតុប៉ះពាល់បរិស្ថាន (EIS) រឺការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) នៅទីតាំងណាមួយជាកំណត់នេះ ត្រូវការតែសេចក្តីសង្ខេបនៃបណ្តាបញ្ហា ដែលបានពិភាក្សានៅក្នុងរបាយការណ៍ ដ៏ទូលំទូលាយដោយឯកសារយោង ។ របាយការណ៍នៃទីកន្លែងណាមួយជាកំណត់ ( Site- spcific report ) ។ ត្រូវបានគេរំពឹងទុកថានឹងសង្កត់ធ្ងន់ទៅលើបណ្តាបញ្ហាដែលទាក់ទិនជាសំខាន់ ទៅនឹងគំរោង រឺសកម្មភាពដែលបានស្នើសុំ ។

## សន្និដ្ឋាន

យុទ្ធសាស្ត្រវាយតំលៃបរិស្ថានកំពុងទទួលបាននៅការចាប់អារម្មយ៉ាងខ្លាំងនៅក្នុងការអនុវត្តន៍ ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) ក្នុងពិភពលោក ។ លំដាប់ដ៏ធំទូលាយនៃកត្តាផ្សេងៗ នៅក្នុងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) អាចតាងអោយកាលាសុវត្ថិភាព និងការព្រួយបារម្ភ ពាក់ពន្ធ័ទៅនឹងការគិតគូរពិចារណានៅក្នុងការរៀបចំផែនការសំរាប់ជួយបង្កើតគុណភាពបរិស្ថាន និង/រឺកាត់បន្ថយអោយដល់កំរិតអប្បបរមានូវការខូចខាតបរិស្ថាន ។ កាលាសុវត្ថិភាពទាំងនេះ ត្រូវបានឆ្លុះតាមរយៈមូលដ្ឋានដ៏សមហេតុសមផលមួយ សំរាប់ជ្រើសរើសតំបន់ភូមិសាស្ត្រ សំរាប់សិក្សានៅក្នុងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA )។ លើសពីនេះទៀត ការធ្វើសេចក្តីសំរេចអំពីទីតាំងគំរោង អាចធ្វើឡើងដោយផ្អែកទៅលើការការពារធម្មជាតិដែលមានតំលៃបំផុត រឺដែលងាយទទួលរងនូវការខូច ។ ការរៀបចំផែនការក៏អាចត្រូវបានគេអនុវត្តផងដែរចេញពីទស្សនៈទានជារួមមួយគឺមិនមែនចេញពីការសង្កត់ធ្ងន់ទៅលើបញ្ហាស្ថាប័ន ដែលប្រកបដោយភាពមានកំរិតនោះទេ ។ បើទោះបីជាយ៉ាងនេះក៏ដោយ ក៏នៅមានការព្រួយបារម្ភជាច្រើន ទាក់ទិនទៅនឹង

ការធ្វើផែនការ និងការប្រតិបត្តិ ការសិក្សាយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA )។ ជាវិបាក ការព្រួយបារម្ភទាំងនោះរួមមាន ៖-

- ការខ្វះខាតលក្ខណៈពិសេស ( Specificity )នៃគោលនយោបាយផែនការ និងកម្មវិធីបរិស្ថាន ( PPP ) ដែលអាចកំណត់នូវការគិតគូរពិ ចារណាមួយហេតុនេះវិធីសាស្ត្រ " Impact footprint " គឺត្រូវការប្រើប្រាស់ជាចាំបាច់
- ការខ្វះខាតផែនការថ្នាក់តំបន់ រឺថ្នាក់ជាតិសំរាប់ជាឯកសារយោង រឺការមានផែនការដែរ តែផែនការនោះមានក៏រឹតដែលមានលក្ខណៈហួសសម័យ
- យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) ទ្រង់ទ្រាយធំ តម្រូវអោយមានកិច្ចខិតខំប្រឹងប្រែងច្រើន ដែលចាំបាច់សំរាប់ការប្រមូលទិន្នន័យអំពី គំរោងផ្សេងៗ ធនធានបរិស្ថាន ច្បាប់ ។ល។
- សមត្ថភាពទទួលបាននៃបរិស្ថាន ( ពោលគឺជីវៈរូបសាស្ត្រ និងសង្គមសេដ្ឋកិច្ច ) ចាំបាច់ត្រូវតែត្រូវបានយកមកគិតគូរពិចារណាហើយនិងការខ្វះខាត់ពតិមាន ស្តីអំពី សមត្ថភាពទទួលបាន រឺផ្ទុកនេះ
- ភាពមិនប្រាកដអាចមានទំហំធំជាងសំរាប់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន( EIA )ក៏រឹតគំរោង
- ការសង្កត់ធ្ងន់ទៅលើហេតុប៉ះពាល់ដំបូងបំផុតនៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) គឺត្រូវតែសង្កត់ធ្ងន់លើហេតុប៉ះពាល់ដែលប្រមូលផ្តុំគ្នាក្នុងរយៈពេលមួយ ( ពោលគឺ ឥទ្ធិពលជះ )
- មានសេចក្តីត្រូវការជាចាំបាច់ និងពិសេសសំរាប់ដោះស្រាយហេតុប៉ះពាល់ឆ្លងព្រំប្រទល់
- ការភាន់ច្រឡំដែលអាចកើតមានដូចជាថាប្រធានបទណាមួយជាកំណត់ ត្រូវធ្វើការដោះស្រាយ នៅពេលណានៅក្នុងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA )មួយ រឺការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) ក៏រឹតគំរោងបន្ទាប់មកទៀត រឺទាំងពីរនោះ ។

# វិធីសាស្ត្រ និងបច្ចេកទេស

~~~~~~~

## វិធីសាស្ត្រ នៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន

ការធ្វើផែនការ និងការអនុវត្តន៏យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) មានការពាក់ពន្ធ័ទៅនឹង ការគិតគូរពិចារណា អំពីចំនួននៃបញ្ហា ។ ការអនុវត្តន៏យុទ្ធសាស្ត្រវាយតំលៃបរិស្ថានដ៏ល្អប្រសើមួយ ត្រូវបញ្ចូលនូវកត្តាមួយចំនួននៅក្នុងក្របខណ្ឌ័នៃការប្រើប្រាស់ដូចខាងក្រោមនេះ ៖-

១- ប្រើប្រាស់របៀបរបបជ្រើសរើសដ៏ងាយមួយដើម្បីចាប់ផ្តើមយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) រឺទាត់ចោលនូវសំណើរមួយចំនួន ចេញពីការគិតគូរពិចារណាជាបន្តបន្ទាប់ ដោយអាស្រ័យទៅលើស្ថានទំនង់នៃហេតុប៉ះពាល់បរិស្ថានរបស់វាដែលគេបានរំពឹងទុក ។ មានវិធីសាស្ត្រជាច្រើន ដែលអាចអោយគេប្រើប្រាស់បានដូចជា តារាងបែងចែកតាមប្រភេទ ( Categorical lists ) ការពិសោធន៏សាល្បង ទៅតាមករណីនិមួយៗ ដើម្បីជ្រើសរើសករណីដែលល្អ ( case by case tests for significance ) ការចោតសួរជាសំណួ រមុនពេលធ្វើការចំរាញ់ជ្រើសរើស ( Pre- screening questions ) រឺមួយវិធីសាស្ត្រចំរុះបញ្ចូលគ្នា នៃវិធីសាស្ត្រទាំងនោះ ។

២- ប្រើប្រាស់វិធីសាស្ត្រកំណត់ទំហំ ( Scoping ) ដើម្បីកំណត់បញ្ហាសំខាន់ៗ ដូចជាការប្រើប្រាស់សេចក្តីព្រាងតួនាទីភារកិច្ច (Term of reference) ដែលចាំបាច់សំរាប់យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) ការកំណត់វិធីសាស្ត្រសំរាប់អនុវត្តន៏ និងការបង្កើតឡើងនូវជំរើសផ្សេងៗដើម្បីធ្វើការគិតគូរពិចារណា ។

៣- កំណត់លក្ខណះពិសេសវាយតំលៃ និងប្រៀបធៀបជំរើសផ្សេងៗ ដោយរាប់បញ្ចូលទាំងគោលដៅជ្រើសរើសដែលគ្មានសកម្មភាព ( No- action Option )។ គោលបំណងរបស់វា គឺដើម្បីបញ្ជាក់អោយច្បាស់លាស់នូវលំនឹង រឺតុល្យភាព (Trade-off) នៅខណះដែលអាចនឹងមានផលអាក្រក់ ដែលបង្ហាញអោយឃើញថាអ្វីដែលចំណេញ និងអ្វីដែលខាត ។ ប្រសិនបើអាចធ្វើបាន គោលដៅជ្រើសរើសនៃបរិស្ថាន ដែលអាចអោយគេអនុវត្តបានដ៏ល្អបំផុតនោះ ត្រូវតែត្រូវបានគេកំណត់ ។

៤- អនុវត្តការវាយតំលៃគោលនយោបាយ រឺការវិភាគហេតុប៉ះពាល់អោយដល់កំរិតមួយ ដែលចាំបាច់ ដើម្បីត្រួតពិនិត្យបញ្ហាបរិស្ថានទាំងឡាយ និងឥទ្ធិពលជះដែលប្រមូលផ្តុំគ្នា ធ្វើការប្រៀបធៀបជំរើសផ្សេងៗ និងធ្វើការកំណត់វិធានការណ៏តែលំអរសំខាន់ៗសំរាប់ការព្រួយបារម្ភផ្សេងៗទៀតដែលនៅសេសសល់ ។

៥- រាយការណ៏ដោយសង្ខេប និងច្បាប់លាស់អំពីលទ្ធផលនៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) ដោយមានភ្ជាប់នូវការណែរនាំ រឺ ដំបូន្មាន និងអនុសាសន៏មួយចំនួន ដូចអ្នកធ្វើសេចក្តីសំរេច ។ គឺអាស្រ័យទៅតាមសំណើនិមួយៗ ឯកសារអាចមាន ទំហំពី ពីរបី ទំព័ រ រហូតដល់របាយការណ៏ដែលមានលក្ខណះពេញលេញ ។
~~~~~~~

៦- ធ្វើការពិនិត្យឡើងវិញ គុណភាពនៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) ដើម្បីធានាថា ពតិមាន គឺមានលក្ខណៈគ្រប់គ្រាន់ និងទាក់ទិនទៅនឹងសេចក្តីត្រូវការរបស់អ្នកធ្វើសេចក្តីសំរេចចិត្ត ។ គឺអាស្រ័យទៅតាមដំណើរការនិមួយៗ សកម្មភាពទាំងនេះអាចមានលក្ខណៈចាប់ពីការចែកពិនិត្យយ៉ាងរហ័ស រឺត្រួសៗ រហូតដល់ការពិនិត្យឡើងវិញប្រកបដោយឯករាជ្យភាព ។

៧- បង្កើតលក្ខ័ខ័ណ្ឌនៃការតាមដានសំខាន់ៗ សំរាប់ត្រួតពិនិត្យឥទ្ធិពលជះផ្សេងៗ ដោយធ្វើការផែកពិនិត្យថា លក្ខ័ខណ្ឌ័ផ្សេងៗនៃបរិស្ថានសំរាប់ការអនុញ្ញាត ត្រូវបានគេប្រតិបត្តិ ហើយចំពោះទីកន្លែងដែលចាំបាច់ ត្រូវធ្វើការតាមដានការរៀបចំផ្សេងៗចំពោះការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) កំរិតគំរោង ដែលពាក់ពន្ធ័ ។ ចំពោះគោលនយោបាយផែនការ និងកម្មវិធី ( PPPs ) ដែលផ្តួចផ្តើមគំរោងការ រៀបចំជាកំរិតជាន់ថ្នាក់ ពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) ទៅជាយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) អាចជួយបង្កើនប្រសិទ្ធិភាពនិងភាពគ្រប់គ្រាន់នៃដំណើរការនេះ ។

ការគិតគួរពិចារណាដ៏ពិស្តារមួយ គឺមិនចេះតែអាចអនុវត្តន៏ចំពោះគ្រប់បញ្ហានិមួយៗ ដែលពាក់ពន្ធ័ទៅនឹងការធ្វើផែនការយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) នោះទេ ។ ផ្ទុយទៅវិញការយកចិត្តទុកដាក់ជាពិសេស នឹងអាចផ្តល់នូវសន្ទស្សន៍ជំរើសផ្សេងៗ និងវិធានការកែលំអរផ្សេងៗ ។

## សន្ទស្សន៍ :

សន្ទស្សន៏អាចត្រូវបានគេប្រើប្រាស់នៅក្នុងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEAs ) ជាមធ្យោបាយសំរាប់អធិប្បាយ អំពីលក្ខ័ខ័ណ្ឌមូលដ្ឋាន ( Baseline conditions ) ធ្វើការព្យាករណ៏ហេតុប៉ះពាល់ និងធ្វើការប្រៀបធៀប ជំរើសផ្សេងៗ ហើយនឹងសំរាប់ត្រួតពិនិត្យប្រសិទ្ធិភាពរយៈពេលវែងនៃគោលនយោបាយផែនការ និងកម្មវិធី ( PPP ) ពិសេសណាមួយ ។ យើងបានធ្វើការពិនិត្យឡើងវិញរួចហើយ នូវសន្ទស្សន៏ វិធីសាស្ត្រផ្សេងៗ នៅក្នុងមេរៀនមួយចំនួនពីខាងដើម ។ សន្ទស្សន៏ខ្លះៗនៃ សន្ទស្សន៏ទាំនេះអាចមានប្រសិទ្ធិភាពសំរាប់យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEAs ) ។ ឧទាហរណ៏ : លទ្ធផលវិភាគនៃកំហាប់ធាតុបារត ដែលបានមកពីការវិភាគជាលិការត្រីដែលនៅសំណាកគំរូដែលបានស្រង់ រឺប្រមូលអាចអោយគេធ្វើការសន្ទត រឺបកស្រាយដើម្បីវាសស្ទង់នូវភាពគ្រោះថ្នាក់នៃសុខភាពពួកមនុស្ស ដែលបរិភោគត្រីទាំងនោះ ។ លើសពីនេះការស្រង់ និងវិភាគសំណាកគំរូនៃទឹកតាមរដូវ រឺកំទិចកំណកដីល្បាប់អាចអោយគេប្រើប្រាស់ដើម្បីវាស់ស្ទង់ប្រសិទ្ធិភាពនៃវិធានការណ៏ការពារគុណភាពទឹកនៅទូទាំងប្រទេសបាន ។ ប្រសិនបើ ប៉ារ៉ាម៉ែត្រមួយចំនួនដូចជា ធាតុលោហៈប្រភេទធ្ងន់ ( Heavy metals ) កាកសំណល់ដែលមានបណ្តុំពពួកបាក់តេរីនៅក្នុងទឹក ( Fecal coliforms ) មានកំរិតខ្ពស់នោះ អ្នកគ្រប់គ្រងបរិស្ថានត្រូវធ្វើការវាយតំលៃទឹក រឺបទដ្ឋានគុណភាពនៃកាកសំណល់រាវនោះឡើងវិញ ហើយប្រសិនបើអាចត្រូវធ្វើយ៉ាងណាអោយបទដ្ឋានទាំងនោះមានលក្ខណៈតឹងរ៉ឹង រឺច្បាស់លាស់ជាងមុន ( ពោលគឺដែលមានការការពារកំរិតខ្ពស់ជាងមុន ) ។ ប្រសិនបើបទដ្ឋានដូចគ្នា រឺស្រដៀងគ្នា ត្រូវបាននិងកំពុងប្រើប្រាស់នៅក្នុងប្រទេសផ្សេងៗទៀត ហើយបទដ្ឋានទាំងនោះកម្រ នឹងត្រូវបានគេអនុវត្តន៏អោយលើសនោះ អ្នកគ្រប់គ្រងបរិស្ថាន

អាចពិនិត្យមើលថា តើកម្មវិធីការពារគុណភាពទឹករបស់ខ្លួនត្រូវបានគេប្រតិបត្តិយ៉ាងដូចម្តេច ។ នោះប្រហែលជាត្រូវបង្កើនការអប់រំ រឺពង្រឹងការអនុវត្តន៏ច្បាប់ រឺការគោរពបទដ្ឋានទាំងនោះ ។

សន្ទស្សន៍ទាំងឡាយត្រូវបំពេញនូវលក្ខណៈសម្បត្តិដូចខាងក្រោម ដើម្បីបង្កើនអោយដល់កំរិតអតិបរមា នូវប្រសិទ្ធិភាពរបស់ខ្លួន ៖-

- សន្ទស្សន៍ គឺមានអត្ថន័យដោយឡែក ( Individually ) និងលក្ខណៈរួម ( Collectively ) ។
- វាតាងអោយបណ្តាបញ្ហាសំខាន់ៗ
- វាឆ្លុះបញ្ចាំងអោយឃើញ ទាំងផលប្រយោជន៏ជាតិ និងផលប្រយោជន៏ថ្នាក់តំបន់ ហើយនិងនិន្នាការនៅមូលដ្ឋាន
- វាអាស្រ័យទៅលើគោលការណ៏ ដែលមានតំលៃអាចប្រើបាន និងការសន្ទត
- វាអាស្រ័យទៅលើភាពងាយស្រួលនៃការប្រមូលពតិមាន ( Relatively easy- to- collect information )
- ជាទស្សនៈទូទៅពតិមានគឺគេអាចរកបានដោយប្រើប្រាស់ពេលវេលាដ៏សមស្របមួយ
- វាអនុញ្ញាតអោយធ្វើការប្រមូលពតិមានបានទាំងគុណភាព និងបរិមាណនៅក្នុងលំហរ ខុសៗគ្នា ( Spatial scales )
- វាអនុញ្ញាតអោយធ្វើការគិតគូរពិចារណាអំពីជំរើសផ្សេងៗដាច់ដោយឡែកពីគ្នា រឺបញ្ចូលគ្នា
- វានាំទៅរកការវាស់ស្ទង់ ពតិមានជាមូលដ្ឋាន ( Baseline imformation ) និងការព្យាករណ៏ ហើយនិងការត្រួតពិនិត្យហេតុប៉ះពាល់ ។
- វាផ្តល់លទ្ធផលដែលមានលក្ខណៈដដែលៗដែលផ្តល់នូវការសន្ទតដ៏ច្បាស់លាស់មួយ ។
- វាជួយសំរួលដល់ការស្រម័យគិតរបស់អ្នកធ្វើសេចក្តីសំរេច និងបង្កើតការយល់ដឹងដ៏ស៊ីជំរៅ របស់ជំរើសដែលត្រូវជ្រើសរើស ។
- វាផ្តល់នូវលទ្ធផលងាយយល់សំរាប់អ្នកធ្វើសេចក្តីសំរេច និងសាធារណៈ

**ជំរើស (Alternatives)**

ជំរើសផ្សេងៗដែលបានដោះស្រាយនៅក្នុងគោលនយោបាយ ផែនការ និងកម្មវិធី ( PPPs ) អាចមានលក្ខណៈទូលំទូលាយហើយប្រហែលជាអាច មានប្រភេទផ្សងគ្នា បើប្រៀបធៀបទៅនឹងជំរើសពិសេសណាមួយ សំរាប់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) កំរិតគំរោង ។ ឧទាហរណ៏ ជំរើសពិសេសសំរាប់គោលនយោបាយ ផែនការ និងកម្មវិធី ( PPPs ) រួមមាន ៖-

- ការដែលមិនធ្វើទាំងអស់ " do nothing " រឺទុកអោយបន្តជាមួយនិងគោលដៅជ្រើសរើស ដែលជានិន្នាការដែលកំពុងកើតមាន ។
- ការកាត់បន្ថយសេចក្តីត្រូវការ ដូចជាការកាត់បន្ថយសេចក្តីត្រូវការទឹក តាមរយៈការកំរិតដោយវង្វាស់កំពស់ រឺប្រវែង ( Water metering )ក៏ដូចជាស្របតាមសេចក្តីត្រូវការ ( Meeting demand )

- វិធីសាស្ត្រដែលប្រើប្រាស់ទៅតាមទីតាំងផ្សេងៗគ្នា ឧទាហរណ៍ការសាងសង់ផ្ទះថ្មីនៅក្នុងទីក្រុងមួយ រឺនៅក្នុងទីក្រុងថ្មី
- ការផ្តល់ការអភិវឌ្ឍន៍ប្រភេទផ្សេងៗគ្នាដែលអាចសំរេចគោលបំណងដូចគ្នា ។ ឧទាហរណ៍ ការផលិថាមពល ដោយប្រើប្រាស់ ឧស្ម័ន ធ្យូងថ្ម ខ្យល់ ។ល។
- វិធានការសារពើពន្ធ ដូចជាការដាក់អោយបង់ថ្លៃផ្លូវ រឺការ បង់ថ្លៃនៃការស្ទះ ( Congestion charges ) ។
- ទ្រង់ទ្រាយនៃការគ្រប់គ្រងផ្សេងៗគ្នា ដូចជាការគ្រប់គ្រងកាកសំណល់ តាមរយៈការផលិតឡើងវិញ ( Recycling ) ការដុតនៅក្នុងឡ ។ល។
- វិធីសាស្ត្រនៃការច្របាច់បញ្ចូលគ្នាកិច្ចអភិវឌ្ឍន៍ និងការគ្រប់គ្រងដែលធ្វើអោយមានលក្ខណៈងាយស្រួល ដូចជា ការដឹកជញ្ជូនដែលមានលក្ខណៈ សាធារណៈ និងឯកជន ។

**វិធានការណ៍កែលំអរ (Mitigation)**

ជាចុងក្រោយ វិធានការទប់ស្កាត់ ដែលអាចមានលក្ខណៈសមស្របនៅក្នុងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEAs ) រួមមាន ៖-

- ការដាក់ផលលំបាកទាំងឡាយទៅលើ រឺការបង្កើតក្របខណ្ឌ័សំរាប់គោលនយោបាយ ផែនការ និងកម្មវិធី នៅកំរិតជាន់ថ្នាក់ទាប ( Lower- tier- PPPs ) ។ នេះអាចរាប់បញ្ចូលនូវសេចក្តីត្រូវការយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEAs ) /ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) របស់គោលនយោបាយ ផែនការ និងកម្មវិធី និងគំរោងនៅកំ រឹតជាន់ថ្នាក់ទាប រឺសេចក្តីត្រូវការពិសេសណាមួយ សំរាប់ប្រតិបត្តិការគំរោងទាំងឡាយដែលជាលទ្ធផលចេញចេញពីគោលនយោបាយ ផែនការ និងកម្មវិធី (PPPs) ។
- ការបង្កើត រឺការផ្តល់ថវិការសំរាប់បង្កើតតំបន់ថ្មីៗសំរាប់ការអភិរក្សធម្មជាតិ រឺកន្លែងកំសាន្ត ។
- ការបង្កើតគោលការណ៍គ្រប់គ្រងសំរាប់ប្រតិបត្តិការ គោលនយោបាយ ផែនការ និងកម្មវិធី ( PPPs ) ។
- ការប្តូរទីតាំង ប្រភេទសត្វព្រៃដែលងាយរងការខូចខាត រឺមានដោយកំម្រ រឺលំនៅដ្ឋានធម្មជាតិរឺ ទីកន្លែងដែលមានភាពជាទីគាប់ចិត្តនៅមូលដ្ឋាន ។
- សេចក្តីត្រូវការដ៏ចាំបាច់ បច្ចេកវិជ្ជា ផលិតកម្មស្អាត ( cleaner production ) ដែលអាចកាត់បន្ថយការបំពុលតាមរយៈការឆេះ រឺចំហេះ សំរាប់ប្រភេទឧស្សាហ៏កម្មផ្សេងៗ នៅក្នុងប្រទេស រឺតំបន់ ។

**បច្ចេកទេសសំរាប់ការអនុវត្តន៍យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន** (SEA)

មានបច្ចេកទេសមួយចំនួន ដែលមានសារៈប្រយោជន៏នៅក្នុងស្ថានភាពនៃការបំពេញតួនាទី ដែលពាក់ព័ន្ធទៅនិងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) ។ បច្ចេកទេសដែលអាចអនុវត្តន៏សំ រាប់យុទ្ធសាស្ត្រវាយតំលៃ ( SEA ) រួមមានប្រភេទបច្ចេកទេសមួយចំនួន សំរាប់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( EIA ) កំរិតគំរោង ក៏ដូចជា បច្ចេកទេស

មួយចំនួនទៀតដែលតែងតែត្រូវបានគេប្រើប្រាស់ជារឿយៗ សំរាប់ការវិភាគគោលនយោបាយ រឺការវាយតំលៃផែនការ ។ ឧទាហរណ៏ នៃក្រុមបច្ចេកទេសដែលប្រើប្រាស់សំរាប់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ( SEA ) ក៏រិតគំរោងមួយ រួមមាន សេណារីយ៉ូ (Scenarios ) តារាងតុល្យភាពផែនការ ( Planning balance sheets ) និងការវិភាគការចំណាយ និងចំណេញ ( Cost benefit analysis ) ។ អាស្រ័យទៅលើលក្ខណៈពិសេសនៃគោលនយោបាយ ផែនការ និងកម្មវិធី ( PPP ) ដែលពាក់ព័ន្ធទៅនិង យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) ការកែសំរួល អាចជាការចាំបាច់ ចំពោះបណ្តាបច្ចេកទេសដែលបានជ្រើសរើសចេញពីក្រុមបច្ចេកទេសទាំងពីរខាងលើ ។ តារាងទី១ បង្ហាញជូននូវឧទាហរណ៏មួយចំនួននៃបច្ចេកទេសផ្សេងៗ ដែលមានការពាក់ព័ន្ធនៅក្នុងដំណាក់កាលខុសៗគ្នា ក្នុងការរៀបចំផែនការនិងការអនុវត្តន៏យុទ្ធសាស្ត្រ វាយតំលៃបរិស្ថាន ( SEA ) មួយ ។ គឺជាប្រការដ៏សំខាន់ក្នុងការកត់សំគាល់ថា គ្មានបច្ចេកទេសទោលតែឯងណាមួយ អាចត្រូវបានប្រើប្រាស់សំរាប់គ្រប់ដំណាក់កាលទាំងអស់ នៅក្នុងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន (SEA) មួយបាននោះទេ ។

ទស្សនៈទានដ៏សំខាន់មួយ នៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន(SEA) គឺពាក់ព័ន្ធទៅនិងការព្យាករណ៏ហេតុប៉ះពាល់ ។ ឧទាហរណ៏ នៃបច្ចេកទេសព្យាករណ៏ហេតុប៉ះពាល់ ដែលអាចត្រូវបានគេប្រើប្រាស់ក្នុងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) រួមមាន ៖-

- តារាងផ្ទៀងផ្ទាត់ ដែលអាចបង្ហាញថាតើគោលនយោបាយ ផែនការ និងកម្មវិធីមួយមានហេតុប៉ះពាល់ រឺទេ ។ ជូនកាលអាចផ្តល់នៅភាពពិស្តារថែមទៀត អំពីឧទាហរណ៏នៃហេតុប៉ះពាល់ ( ពោលគឺ វិជ្ជមាន អវិជ្ជមាន ) និងទំហំរបស់វា ។
- ការវាយតំលៃភាពស៊ីសង្វាក់គ្នា រឺសង្គតភាពដែលអាចវាស់ស្ទង់អោយដឹងថា តើសមាសភាគរងផ្សេងៗគ្នានៃគោលនយោបាយ ផែនការ និងកម្មវិធី ( PPP ) មានសង្គតភាពផ្ទៃក្នុងរវាងគ្នា ដែរ រឺទេ ? ។
- ការវិភាគសេណារីយ៉ូ ( Scenarios analysis )
- ផែនទី រឺប្រព័ន្ធពតិមានភូមិសាស្ត្រ ( GIS ) ដែលអាចបង្ហាញ ឧទាហរណ៏ ទីតាំងដែលបានទទួលរងឥទ្ធិពលដោយគោលនយោបាយ ផែនការ និង កម្មវិធី ( PPP ) ។
- តួលេខ រឺសន្ទស្សន៏ផ្សេងៗគ្នា និង/រឺបច្ចេកទេសវាស់ស្ទង់ស្ថានទំងន់ ( Weighting techniques ) ដូចជាតួលេខបង្ហាញពីនិរន្តរភាព នៃលំនៅដ្ឋានធម្មជាតិ ។
- ការបង្កើតជាគំរូដោយប្រើ Computer ដូចជាគំរូ ដែលអាចព្យាករណ៏ការបំពុលខ្យល់ដោយផ្អែកលើសន្ទត់ពាក់ព័ន្ធទៅនឹងប្រភេទចំនួន អត្រាកាន់កាប់ ( Occupancy rate ) នៃយានយន្ត ហើយនិងការប្រើប្រាស់ប្រេងឥន្ធនៈ ។
- ទស្សនៈ រឺ គំនិតរបស់អ្នកជំនាញការ ។

**តារាងទី១ ៖ វិធីសាស្ត្រដែលមានសារៈប្រយោជន៍ ក្នុងការបំពេញដំណាក់កាលនានាំទូលាយ នៃយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន** ( SEA )

| ដំណាក់កាល រឺជំហ៊ាន | ឧទាហរណ៏ នៃវិធីសាស្ត្រ |
|---|---|
| ការសិក្សាមូលដ្ឋាន<br>( Baseline Study ) | ● របាយការណ៏ស្តីពីស្ថានភាពបរិស្ថាន និងបណ្តាឯកសារដែលមានលក្ខណៈស្រដៀងគ្នា<br>● ធនធានបំរុងនៃបរិស្ថាន ( Environment stocklsetting ) |
| ការចំរាញ់ រឺការកំណត់ទំហំ<br>( Screening / Scooping ) | - តារាងផ្សេងផ្ទាត់ផ្លូវការ រឺក្រៅផ្លូវការ<br>- ការសង្កេតលើបណ្តា ករណីដែលអាចប្រៀបធៀបបាន<br>- បណ្តាញទាក់ទិនប្រកបដោយប្រសិទ្ធិភាព ( Effects networks )<br>- ការពិគ្រោះយោបល់ជាសាធារណៈ រឺជាមួយអ្នកជំនាញ |
| ការកំណត់គោលដៅជ្រើសរើស ( Definition Option ) | - គោលនយោបាយបទដ្ឋាន និងយុទ្ធសាស្ត្របរិស្ថាន<br>- ការប្តេជ្ញាចិត្តដែលធ្លាប់មានពីមុនមក<br>- ផែនការថ្នាក់តំបន់ រឺថ្នាក់មូលដ្ឋាន<br>- តំលៃជាសាធារណៈ និងការនិយមចូលចិត្ត |
| ការវិភាគហេតុប៉ះពាល់<br>( Impact Analysis ) | - ការបង្កើតសេណារីយ៉ូ ( Scenario development )<br>- ការវាយតំលៃភាពងាយរងគ្រោះថ្នាក់<br>- សន្ទស្សន៏ និងលក្ខណៈវិនិច្ឆ័យបែបបរិស្ថាន<br>- តារាងហេតុកប៉ះពាល់ខាងផ្នែកគោលនយោបាយ<br>- គំរូសំរាប់ព្យាករណ៏ និងសំរាប់ធ្វើតាម ( Predictive and simulation models )<br>- សមត្ថភាពនៃប្រពន្ឋ័ពតិមានភូមិសាស្ត្រ រឺការវិភាគអំពី លំនៅដ្ឋានធម្មជាតិ<br>- ការវិភាគប្រសិទ្ធិភាពដោយផ្អែកលើការចំណេញ និងខាត និងបច្ចេកទេសវាយតំលៃសេដ្ឋកិច្ចផ្សេងៗ<br>- ការវិភាគដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្រើនយ៉ាង |
| ការចងក្រងជាឯកសារសំរាប់ការធ្វើសេចក្តីសំរេច<br>( Documentation for Decision Making ) | - តារាងវាយតំលៃហេតុប៉ះពាល់ ( Cross- impact matrices )<br>- ការវិភាគដោយសង្គតភាព ( Consistency analysis )<br>- ការវិភាគលើភាពងាយប្រែប្រួល ( Sensitively analysis )<br>- ការធ្វើសេចក្តីសំរេចតាមរបៀបមែកឈើ ( Decision trees ) |

តារាងទី២ ៖ ធ្វើការសង្ខេបដោយផ្អែកទៅលើមូលដ្ឋាននៃការពាក់ពន្ធ័គ្នា នូវការប្រើប្រាស់បច្ចេកទេស វាយតំលៃហេតុប៉ះពាល់បរិស្ថានជាច្រើនប្រភេទ សំរាប់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន លើគំរោងមួយជាកំណត់ ការវាយតំលៃឥទ្ធិពលជះដែលប្រមូលផ្ដុំគ្នា ក្នុងរយៈពេលមួយ ( CEA ) និងសំរាប់យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) ។ គេគួរកត់សំគាល់ថា ក្នុងការប្រើប្រាស់ជាក់ស្ដែងនូវបច្ចេកទេសនិមួយៗខាងលើ មានការប្រែប្រួលផ្សេងៗគ្នាតិចតួច រវាងការវាយតំលៃនៅថ្នាក់គំរោង និងការវាយតំលៃនៅកំរឹតនៃការរៀបចំយុទ្ធ សាស្ត្រ សំរាប់អនុវត្តន៏ ។

សរុបមកវិញ នៅពេលដែលបច្ចេកទេសសំរាប់យុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) ត្រូវបានគេរៀបចំបញ្ចូលនៅក្នុងតារាងបច្ចេកទេសទាំងនោះ មិនត្រូវបានគេបង្កើតឡើងដោយប្រាជកប្រជា ហើយមិនមានលក្ខណៈល្អប្រសើដូចបច្ចេកទេសសំរាប់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅថ្នាក់គំរោងនោះទេ ។ ការសិក្សាដែលមានលក្ខណៈស្រដៀងគ្នានេះ គឺជាប្រការចាំបាច់ដែលត្រូវផ្តោតទៅលើអត្ថប្រយោជន៏ និងប្រសិទ្ធិភាពនៃបច្ចេកទេសប្រភេទផ្សេងៗគ្នា នៅក្នុងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA ) ។

**តារាងទី ២ :** បច្ចេកវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានប្រើប្រាស់នៅក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ការវាយតំលៃតទ្ធិពលជះដែលប្រមូលផ្តុំគ្នាក្នុងរយៈពេលមួយ ( CEA )និងយុទ្ធសាស្ត្រវាយតំលៃបរិស្ថាន ( SEA )

| ប្រភេទនៃវិធីសាស្ត្រ | កំរឹតនៃការប្រើប្រាស់ | | |
|---|---|---|---|
| | ការវាយតំលៃហេតុប៉ះពាល់បរិស្ថានកំរឹតគំរោង | CEA | SEA |
| ភាពដូចគ្នា ( Analogs ) | H | M | L |
| តារាងផ្ទៀងផ្ទាត់ ( Checklists ) | H | M | M |
| តារាងផ្ទៀងផ្ទាត់សំរាប់ការធ្វើសេចក្តីសំរេចចិត្ត | | | |
| ( Decision- focused- checklists ) | M | L | L |
| ការខាត និងចំណេញ ( Cost- Benefit Analysis ) | | | |
| ទស្សនៈនៃអ្នកជំនាញការ ( Expert Opinion ) | L | O | O |
| ប្រពន្ធ័អ្នកជំនាញការ ( Expert System ) | H | M | M |
| តួលេខ រឹសន្ទស្សន៍ | L | O | O |
| ការពិសោធន៍សាកល្បងនៅក្នុងមន្ទីរពិសោធន៍ | | | |
| | M | L | M |
| ការវាយតំលៃដោយផ្អែកលើទេសភាព ( Landscape Evaluation ) | M | L | NA |
| ការស្រាវជ្រាវលើឯកសារតុល្យភាពនៃម៉ាស់ ( Mass Balances ) | | | |
| តារាងម៉ាទ្រិត ( Matrices ) | M | L | L |
| ការត្រួតពិនិត្យ ( ទិន្នន័យមូលដ្ឋាន ) | H | L | L |
| បណ្តាញការងារ ( Networks ) | | | |
| | H | L | L |
| ផែនទី ( Overlay Mpping ) | L | O | O |
| រូបថត ( Photographs Photo- montages ) | M | O | O |
| គំរូគុណភាព ( Quantitative Models ) | | | |
| | M | L | L |
| ការវាយតំលៃភាពគ្រោះថ្នាក់ ( Risk Assessment ) | | | |
| ការបង្កើតសេនារីយ៉ូ ( Scenario Building ) | | | |
| ការធ្វើចំកណ្តាលនៃទិន្នាការ រឺទំនោរ ( Trend Extrapolation ) | M | L | L |
| | L | L | L |
| | L | O | L |
| | L | L | L |

**<u>សំគាល់:</u>**

H = កំរិតប្រើប្រាស់ខ្ពស់ ( Relatively high usage )

M = កំរិតប្រើប្រាស់មធ្យម ( Relatively moderate usage )

L = កំរិតប្រើប្រាស់ទាប( Relatively Low usage )

O = ការប្រើប្រាស់មានកំរិត ( Limited usage; if at all )

NA = មិនអាចប្រើប្រាស់បាន ( Not applicable )